ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ..........................

**កំណត់ហេតុ**
**កិច្ចប្រជុំ ស្តីពី ការពិនិត្យ និងរៀបចំផែនការសកម្មភាព**
**សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៤ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

ថ្ងៃសុក្រ បីរោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស ពីរពាន់ប្រាំរយហុកសិបប្រាំបី ត្រូវនឹងថ្ងៃទីម្ភៃ ខែកញ្ញា ឆ្នាំពីរពាន់ម្ភៃបួន វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានរៀបចំកិច្ចចង្អៀត លើកទី២ ដើម្បីពិនិត្យ និងសម្រេចក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៤ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង ឯកឧត្តម **ខួន រតនៈ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។

គោលបំណងនៃកិច្ចប្រជុំ គឺដើម្បីពិភាក្សា និងកំណត់ជ្រើសរើសយកសកម្មភាពជាអាទិភាព របស់ក្រុមការងារជំនួយកិច្ចការអន្តរក្រសួងទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្នុងការអនុវត្តឱ្យសម្រេចបានក្នុងត្រីមាសទី៤ ឆ្នាំ២០២៤។

**ក. សមាសភាពចូលរួមមាន៖**

-លោកជំទាវ **ប៊ុណ្ណា សំខាន់** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- ប្រធាន អនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- ប្រធាន អនុប្រធានក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- នាយ នាយរងការិយាល័យ ព្រមទាំងមន្ត្រីបច្ចេកទេស សរុបចំនួន ២៦នាក់ ស្រី០៦នាក់។

ជាកិច្ចចាប់ផ្តើម លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ធ្វើការសំណេះសំណាល និងបានរំលឹកឡើងវិញជារឿយៗ នូវបទពិសោធន៍ក្នុងការរៀបចំផែនការជាអទិភាពជាចម្បងសម្រាប់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្នុងការអនុវត្តសកម្មភាព ដើម្បីឱ្យមានរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ឆ្នាំ សម្រាប់គោរពរាយការណ៍ជូនថ្នាក់ដឹកនាំ។ លោកជំទាវបានរកវិធីសាស្ត្ររៀបចំជាគន្លឹះសំខាន់ៗ ឱ្យក្រុមការងារទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្នុងការជ្រើសរើសសកម្មភាពការងារជាអាទិភាព ដែលបានដកស្រង់ចេញពីផែនការយុទ្ធសាស្ត្រជាតិ ចំនួន ១៤សកម្មភាព ជាការងារស្នូលរបស់អគ្គលេខាធិការដ្ឋាន និងដោយបានបែងចែកភារកិច្ចទទួលខុសត្រូវតាមក្រុមរៀងៗខ្លួន។

**ខ. លទ្ធផលនៃកិច្ចប្រជុំ**

ជាកិច្ចបន្ទាប់ ពីធ្វើការសំណេះសំណាលរួច លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ ក៏បានដឹកនាំកិច្ចប្រជុំ បន្តដោយបានណែនាំឱ្យក្រុមជំនួយកិច្ចការទាំង៦ ធ្វើបទបង្ហាញអំពីផែនការសកម្មភាពអាទិភាពសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៤ តាមលំដាប់លំដោយរៀងៗខ្លួន៖

១.ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ធ្វើបទបង្ហាញដោយលោកឧត្តមសេនីយ៍ត្រី **អ៊ិន មាន** ប្រធានក្រុមជំនួយកិច្ចការ បានលើកឡើងថា បានរៀបចំផែនការសកម្មភាពរួចរាល់ ដែលបាននឹងកំពុងអនុវត្ត ចេញជាលទ្ធផលបន្តបន្ទាប់ និងត្រូវបានអនុវត្តបន្តទៀត។

២.**ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ** ធ្វើបទបង្ហាញដោយលោកឧត្តមសេនីយ៍ទោ **សេក ស៊ីវេត** ប្រធានក្រុមជំនួយកិច្ចការះ បានរៀបចំផែនការរួចរាល់ ប៉ុន្តែការអនុវត្តមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយ។

៣.**ក្រុមជំនួយកិច្ចអនុវត្តច្បាប់** ធ្វើបទបង្ហាញដោយឯកឧត្តមឧត្តមសេនីយ៍ត្រី **តែ សុថារ៉េត** អគ្គលេខាធិការរងទទួលបន្ទុកះ បានរៀបចំផែនការសកម្មភាពរួចហើយ តែមិនទាន់បានអនុវត្ត។

៤.**ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍** ធ្វើបទបង្ហាញដោយឯកឧត្តមឧត្តមសេនីយ៍ឯក **ខៀវ ច័ន្ទរ៉ា** អគ្គលេខាធិការរងទទួលបន្ទុកះ បានរៀបចំផែនការសកម្មភាពរួចហើយដែរ តែត្រូវអនុវត្តសកម្មភាពបានមួយចំនួនតូច កំពង់តែរៀចំផែការឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីអនុវត្តបន្ត។

៥.**ក្រុមជំនួយកិច្ចការយុត្តិធម៌** តំណាងដោយឯកឧត្តមសេនីយ៍ទោ **នី គឹមស្រេន** អគ្គលេខាធិការរងទទួលបន្ទុក កំពុងតែរៀបចំផែនការសកម្មភាព សម្រាប់ការអនុវត្ត។

៦.**ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់** តំណាងដោយលោកឧត្តមសេនីយ៍ទោ **សាង រំដោះ** ប្រធានក្រុមជំនួយកិច្ចការ ពុំទាន់បានការឆ្លើយតបទេ ដោយសារក្រុមរបស់គាត់ចុះបេសកកម្មនៅតាមខេត្ត តែក្រុមគាត់កំពុងរៀបចំផែនការសកម្មភាពនេះហើយ សម្រាប់ការអនុវត្ត។

បន្ទាប់មកឯកឧត្តម **យ៉ែម ចាន់ណារុំ** ក៏បានមានប្រសាសន៍ លើកឡើងអំពីបទពិសោធន៍ការងារក្នុងការរៀបចំផែនការមួយចំនួន ដែលបានអនុវត្តកន្លងមក ដើម្បីជាគន្លឹសក្នុងការរៀបចំផែនឱ្យកាន់តែប្រសើរឡើង សម្រាប់ក្រុមការងារទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

សរុបសេចក្តីមក កិច្ចប្រជុំក្នុងការរៀបចំផែនការសកម្មភាពរបស់ក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ពុំទទួលបានសម្រេចជាលទ្ធផលទេ ដោយសារក្រុមការងារជំនួយកិច្ចការមួយចំនួនពុំទាន់បានរៀបចំផែនការរបស់ខ្លួនគ្រប់ជ្រុងជ្រោយនៅឡើយ។

ជាទីបញ្ចប់ **លោកជំទាវអនុប្រធាបអចិន្ត្រៃយ៍** ក៏បានមានប្រសាសន៍ណែនាំ និងសូមឱ្យក្រុមនីមួយៗខិតខំប្រឹងប្រែងរៀបចំបញ្ចប់ផែនការនេះឱ្យបានឆាប់ ដោយឱ្យពិនិត្យឡើងវិញនូវចំណុចគន្លឹសទាំង ១៤ចំណុច ទៅតាមសកម្មភាពនីមួយៗ របស់ខ្លួន ដើម្បីយកមកប្រៀបធៀបបញ្ចូលគ្នា ដោយស្នើសុំឱ្យ**លោកជំទាវ អគ្គលេខាធិការ** គ.ជ.ប.ជ ធ្វើការដឹកនាំពិនិត្យ និងសម្របសម្រួលក្នុងកិច្ចប្រជុំលើកទី៣ ខាងមុខនេះ។

កិច្ចប្រជុំ បានបញ្ចប់នៅវេលាម៉ោង ប្រាំ និងសូន្យនាទីល្ងាច ថ្ងៃ ខែ ឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងភាពស្និទ្ធស្នាល។

*ថ្ងៃ សុក្រ ៦ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨*

*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤*

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក.អ៊ុច ចាន់ធា

*បានឃើញ និងបញ្ជូនមក*

*លោកជំទាវអគ្គលេខាធិការ មេត្តាជ្រាបជារបាយការណ៍*

**ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប**

ឧត្តមសេនីយ៍ទោ. ថោង_វុទ្ធី

26/09/2024.

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៊ុណ្ណ សំខាន់